ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:១៨១ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការបោះពុម្ពសារព្រមានសុខភាពលើកញ្ចប់បារី

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៦/០០២ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញា ស្តីពីការត្រួតពិនិត្យថ្នាំជក់
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៩

www.pheakdeylaw.com

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា១.-

អនុក្រឹត្យនេះមានគោលដៅគ្រប់គ្រង ការបោះពុម្ពសារព្រមានសុខភាពលើកញ្ចប់បារី នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា២.-

អនុក្រឹត្យនេះមានគោលបំណងជាអាទិ៍ ៖

- ការពារសុខុមាលភាពរបស់ប្រជាពលរដ្ឋ
- បង្កើនប្រសិទ្ធភាពលើការត្រួតពិនិត្យកញ្ចប់បារី
- កាត់បន្ថយការប្រើប្រាស់ថ្នាំជក់
- អប់រំផ្សព្វផ្សាយអំពីផលវិបាកនៃការប្រើប្រាស់ថ្នាំជក់ ។

មាត្រា៣.-

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តលើកញ្ចប់បារីគ្រប់ប្រភេទ ដែលចែកចាយនិងលក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា៤.-

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះមាននិយមន័យដូចតទៅ ៖

- កញ្ចប់បារី សំដៅដល់ប្រអប់ទាំងឡាយ ក្រដាស គ្រឿងរុំពីក្រៅ ឬអ្វី១សម្រាប់ដាក់បារី
- សារព្រមានសុខភាព សំដៅដល់សារជាភាសាខ្មែរ ដែលបោះពុម្ពលើកញ្ចប់បារី បង្ហាញពីគ្រោះថ្នាក់នៃការប្រើប្រាស់ថ្នាំជក់ ។

ជំពូកទី២

សមត្ថកិច្ចគ្រប់គ្រង

មាត្រា៥.-

ការបោះពុម្ពសារព្រមានសុខភាពលើកញ្ចប់បារី ដូចមានចែងក្នុងជំពូកទី ៣ នៃអនុក្រឹត្យនេះ ត្រូវស្ថិតនៅក្រោមការណែនាំ និងត្រួតពិនិត្យរបស់ក្រសួងសុខាភិបាល ។

ជំពូកទី៣

វិធានការបោះពុម្ពសារព្រមានសុខភាពលើកញ្ចប់បារី

មាត្រា៦.-

បារីដែលផលិតក្នុងស្រុក ឬនាំចូលសម្រាប់ធ្វើការចែកចាយនិងលក់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបោះពុម្ពសារព្រមានសុខភាពជាភាសាខ្មែរលើកញ្ចប់បារី ស្តីពីគ្រោះថ្នាក់នៃការប្រើប្រាស់ថ្នាំជក់ ។

សារព្រមានសុខភាពត្រូវតែងាយអាន ងាយមើល ជាក់ច្បាស់ មិនឆ្លុកពណ៌ មិនរលុបអក្សរ ។

www.pheakdeylaw.com

មាត្រា៧.-

ទំហំនិងទីតាំងនៃសារព្រមានសុខភាព ដែលត្រូវបោះពុម្ពលើកញ្ចប់បារី ត្រូវឆ្លើយតបនឹងលក្ខណៈពិសេសដូចខាងក្រោម ៖

- សារព្រមានសុខភាព ត្រូវមានទំហំ ៣០ (សាមសិប) ភាគរយយ៉ាងតិច
- សារព្រមានសុខភាព ត្រូវបោះពុម្ពលើផ្ទៃសំខាន់ ទាំងសងខាង ។

មាត្រា៨.-

គំរូសារព្រមានសុខភាពស្របតាមមាត្រា ៦ និងមាត្រា ៧ នៃអនុក្រឹត្យនេះ និងរបៀបនៃការផ្លាស់ប្តូរគំរូសារព្រមានសុខភាព ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

ជំពូកទី៤

ទណ្ឌកម្ម

មាត្រា៩.-

ផលិតករក្នុងស្រុក អ្នកនាំចូលសម្រាប់ធ្វើការចែកចាយនិងលក់ ដែលមិនគោរពតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មដូចតទៅ ៖

- ព្រមានជាលាយលក្ខណ៍អក្សរ
- ផ្អាកការប្រកបអាជីវកម្មជាបណ្តោះអាសន្ន
- បិទអាជីវកម្មជាស្ថាពរ ក្នុងករណីមិនរាងចាល ។

ចំពោះការផ្អាកការប្រកបអាជីវកម្មជាបណ្តោះអាសន្ន និងការបិទអាជីវកម្មជាស្ថាពរ ត្រូវសុំការយល់ព្រមជាមុនពីប្រមុខរាជរដ្ឋាភិបាល ។

ជំពូកទី៥

អន្តរប្បញ្ញត្តិ

មាត្រា១០.-

បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន ផលិតករក្នុងស្រុក និងអ្នកនាំចូលសម្រាប់ធ្វើការចែកចាយនិងលក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា មានរយៈពេល ៤ (ប្រាំបួន) ខែ សម្រាប់បោះពុម្ពសារព្រមានសុខភាពជាភាសាខ្មែរលើកញ្ចប់បារី ។

www.pheakdeylaw.com

ជំពូកទី៦
អវសានប្បញ្ញត្តិ

មាត្រា១១.-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា១២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០០៥

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com